**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៣៧ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្តីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីមុខតំណែងនិងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់មន្ត្រីបម្រើការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២ .-**

មុខតំណែងនិងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១និងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

មុខតំណែងនិងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន ត្រូវប្រើជាមូលដ្ឋានសម្រាប់ការជ្រើសរើសមន្ត្រីបំពេញការងារក្នុងមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន ការរៀបចំលក្ខខណ្ឌការងារឬកិច្ចព្រមព្រៀងការងារ ការអភិវឌ្ឍសមត្ថភាព ការវិវត្តអាជីព និងការរៀបចំផែនការធនធានមនុស្សស្របតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

**មាត្រា៣ .-**

ការបង្កើត ការលុប និងការកែសម្រួលមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់ក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៦
ស្តីពីការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន

## បញ្ជីឈ្មោះមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន

| ល.រ. | មុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន | លេខកូដ |
|---|---|---|
| **ក. មុខតំណែងបង្រៀននៅមត្តេយ្យសិក្សា** | | |
| ១ | ទារកវប្បករ | PED001 |
| ២ | គ្រូបង្រៀនមត្តេយ្យសិក្សា | PED002 |
| ៣ | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសប្រឹក្សាគរុកោសល្យអប់រំកុមារតូច | PED003 |
| **ខ. មុខតំណែងបង្រៀននៅមត្តេយ្យសិក្សាអប់រំពិសេស** | | |
| ៤ | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសពិការសតិបញ្ញានិងអូទីស្សឹម | PED004 |
| ៥ | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសគថ្លង់ | PED005 |
| ៦ | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសពិការភ្នែក | PED006 |
| **គ. មុខតំណែងបង្រៀននៅបឋមសិក្សា** | | |
| ៧ | គ្រូបង្រៀនបឋមសិក្សា | PED007 |
| ៨ | គ្រូបង្រៀនបឋមសិក្សាភាសាបរទេស | PED008 |
| ៩ | គ្រូបង្រៀនបឋមសិក្សាបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ | PED009 |
| ១០ | គ្រូបង្រៀនបឋមសិក្សាប្រឹក្សាតាមសាលារៀន | PED010 |
| ១១ | គ្រូបង្រៀនបឋមសិក្សាប្រឹក្សាគរុកោសល្យ | PED011 |
| ១២ | គ្រូបង្រៀនបឋមសិក្សាកសិកម្ម | PED012 |
| ១៣ | គ្រូបង្រៀនបឋមសិក្សាពហុភាសាជនជាតិដើមភាគតិច | PED013 |
| **ឃ. មុខតំណែងបង្រៀននៅបឋមសិក្សាអប់រំពិសេស** | | |
| ១៤ | គ្រូបង្រៀនបឋមសិក្សាឯកទេសពិការសតិបញ្ញានិងអូទីស្សឹម | PED014 |
| ១៥ | គ្រូបង្រៀនបឋមសិក្សាឯកទេសគថ្លង់ | PED015 |
| ១៦ | គ្រូបង្រៀនបឋមសិក្សាឯកទេសពិការភ្នែក | PED016 |
| **ង. មុខតំណែងបង្រៀននៅអនុវិទ្យាល័យ** | | |
| ១៧ | គ្រូបង្រៀនអនុវិទ្យាល័យគណិតវិទ្យា | PED017 |
| ១៨ | គ្រូបង្រៀនអនុវិទ្យាល័យភាសាខ្មែរ | PED018 |
| ១៩ | គ្រូបង្រៀនអនុវិទ្យាល័យរូបវិទ្យា | PED019 |
| ២០ | គ្រូបង្រៀនអនុវិទ្យាល័យគីមីវិទ្យា | PED020 |
| ២១ | គ្រូបង្រៀនអនុវិទ្យាល័យប្រវត្តិវិទ្យា | PED021 |
| ២២ | គ្រូបង្រៀនអនុវិទ្យាល័យភូមិវិទ្យា | PED022 |

| ល.រ. | មុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន | លេខកូដ |
|---|---|---|
| ២៣ | គ្រូបង្រៀនអនុវិទ្យាល័យគេហសេដ្ឋកិច្ច | PED023 |
| ២៤ | គ្រូបង្រៀនអនុវិទ្យាល័យសីលធម៌ពលរដ្ឋវិជ្ជា | PED024 |
| ២៥ | គ្រូបង្រៀនអនុវិទ្យាល័យជីវវិទ្យា | PED025 |
| ២៦ | គ្រូបង្រៀនអនុវិទ្យាល័យផែនដីវិទ្យាបរិស្ថាន | PED026 |
| ២៧ | គ្រូបង្រៀនអនុវិទ្យាល័យភាសាបរទេស | PED027 |
| ២៨ | គ្រូបង្រៀនអនុវិទ្យាល័យអប់រំកាយនិងកីឡា | PED028 |
| ២៩ | គ្រូបង្រៀនអនុវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ | PED029 |
| ៣០ | គ្រូបង្រៀនអនុវិទ្យាល័យអប់រំសិល្បៈ | PED030 |
| ៣១ | គ្រូបង្រៀនអនុវិទ្យាល័យអប់រំសុខភាព | PED031 |
| ៣២ | គ្រូបង្រៀនអនុវិទ្យាល័យប្រឹក្សាតាមសាលារៀន | PED032 |
| ៣៣ | គ្រូបង្រៀនអនុវិទ្យាល័យប្រឹក្សាគរុកោសល្យ | PED033 |
| ៣៤ | គ្រូបង្រៀនអនុវិទ្យាល័យកសិកម្ម | PED034 |
| ៣៥ | គ្រូបង្រៀនអនុវិទ្យាល័យអប់រំបំណិនជីវិត | PED035 |
| **ច. មុខតំណែងបង្រៀននៅអនុវិទ្យាល័យអប់រំពិសេស** | | |
| ៣៦ | គ្រូបង្រៀនអនុវិទ្យាល័យឯកទេសពិការសតិបញ្ញានិងអូទីស្សឹម | PED036 |
| ៣៧ | គ្រូបង្រៀនអនុវិទ្យាល័យឯកទេសគថ្លង់ | PED037 |
| ៣៨ | គ្រូបង្រៀនអនុវិទ្យាល័យឯកទេសពិការភ្នែក | PED038 |
| **ឆ. មុខតំណែងបង្រៀននៅវិទ្យាល័យ** | | |
| ៣៩ | គ្រូបង្រៀនវិទ្យាល័យភាសាខ្មែរ | PED039 |
| ៤០ | គ្រូបង្រៀនវិទ្យាល័យគណិតវិទ្យា | PED040 |
| ៤១ | គ្រូបង្រៀនវិទ្យាល័យរូបវិទ្យា | PED041 |
| ៤២ | គ្រូបង្រៀនវិទ្យាល័យគីមីវិទ្យា | PED042 |
| ៤៣ | គ្រូបង្រៀនវិទ្យាល័យប្រវត្តិវិទ្យា | PED043 |
| ៤៤ | គ្រូបង្រៀនវិទ្យាល័យភូមិវិទ្យា | PED044 |
| ៤៥ | គ្រូបង្រៀនវិទ្យាល័យជីវវិទ្យា | PED045 |
| ៤៦ | គ្រូបង្រៀនវិទ្យាល័យផែនដីបរិស្ថានវិទ្យា | PED046 |
| ៤៧ | គ្រូបង្រៀនវិទ្យាល័យសីលធម៌ពលរដ្ឋវិជ្ជា | PED047 |
| ៤៨ | គ្រូបង្រៀនវិទ្យាល័យសេដ្ឋកិច្ច | PED048 |
| ៤៩ | គ្រូបង្រៀនវិទ្យាល័យគេហសេដ្ឋកិច្ច | PED049 |
| ៥០ | គ្រូបង្រៀនវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ | PED050 |

| ល.រ. | មុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន | លេខកូដ |
|---|---|---|
| ៥១ | គ្រូបង្រៀនវិទ្យាល័យអប់រំកាយនិងកីឡា | PED051 |
| ៥២ | គ្រូបង្រៀនវិទ្យាល័យអប់រំសុខភាព | PED052 |
| ៥៣ | គ្រូបង្រៀនវិទ្យាល័យភាសាបរទេស | PED053 |
| ៥៤ | គ្រូបង្រៀនវិទ្យាល័យប្រឹក្សាតាមសាលារៀន | PED054 |
| ជ. មុខតំណែងបង្រៀនបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនិងគ្រឹះស្ថានមធ្យមសិក្សាអប់រំបច្ចេកទេស | | |
| ៥៥ | គ្រូបង្រៀនវិទ្យាល័យរោងជាង | PED055 |
| ៥៦ | គ្រូបង្រៀនវិទ្យាល័យប្រឹក្សាអាជីព | PED056 |
| ៥៧ | គ្រូបង្រៀនវិទ្យាល័យប្រឹក្សាតាមសាលារៀន | PED057 |
| ៥៨ | គ្រូបង្រៀនវិទ្យាល័យប្រឹក្សាគរុកោសល្យ | PED058 |
| ៥៩ | គ្រូបង្រៀនវិទ្យាល័យកសិកម្ម | PED059 |
| ៦០ | គ្រូបង្រៀនឯកទេសបណ្ណារក្ស | PED060 |
| ៦១ | គ្រូបង្រៀនគ្រប់គ្រងបន្ទប់ពិសោធន៍ | PED061 |
| ៦២ | គ្រូបង្រៀនអគ្គិសនី | PED062 |
| ៦៣ | គ្រូបង្រៀនអេឡិចត្រូនិក | PED063 |
| ៦៤ | គ្រូបង្រៀនមេកានិក | PED064 |
| ៦៥ | គ្រូបង្រៀនពាណិជ្ជកម្មអេឡិចត្រូនិក | PED065 |
| ៦៦ | គ្រូបង្រៀនស្វ័យប្រវត្តិកម្ម | PED066 |
| ៦៧ | គ្រូបង្រៀនស្ថាបត្យកម្ម | PED067 |
| ៦៨ | គ្រូបង្រៀនសំណង់ស៊ីវិល | PED068 |
| ៦៩ | គ្រូបង្រៀនវិស្វកម្មលោហៈ | PED069 |
| ៧០ | គ្រូបង្រៀនបន្ទះបន្សារ | PED070 |
| ៧១ | គ្រូបង្រៀនរថនាម៉ូត | PED071 |
| ៧២ | គ្រូបង្រៀនបរិក្ខារត្រជាក់ | PED072 |
| ៧៣ | គ្រូបង្រៀនយន្តសាស្ត្រ | PED073 |
| ៧៤ | គ្រូបង្រៀនគ្រឿងយន្តកសិកម្ម | PED074 |
| ៧៥ | គ្រូបង្រៀនវិទ្យាសាស្ត្រកុំព្យូទ័រ | PED075 |
| ៧៦ | គ្រូបង្រៀនឌីជីថលមេឌៀឌីហ្សាញ | PED076 |
| ៧៧ | គ្រូបង្រៀនបច្ចេកវិទ្យាឌីជីថល | PED077 |
| ៧៨ | គ្រូបង្រៀនបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត | PED078 |

| លរ. | មុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន | លេខកូដ |
|---|---|---|
| ៧៩ | គ្រូបង្រៀនវិស្វកម្មការផលិត | PED079 |
| ៨០ | គ្រូបង្រៀនទូរគមនាគមន៍ | PED080 |
| ៨១ | គ្រូបង្រៀនភស្តុភាកម្ម | PED081 |
| ៨២ | គ្រូបង្រៀនគណនេយ្យ | PED082 |
| ៨៣ | គ្រូបង្រៀនធនាគារនិងហិរញ្ញវត្ថុ | PED083 |
| ៨៤ | គ្រូបង្រៀនទីផ្សារ | PED084 |
| ៨៥ | គ្រូបង្រៀនទេសចរណ៍ | PED085 |
| ៨៦ | គ្រូបង្រៀនសណ្ឋាគារនិងបដិសណ្ឋារកិច្ច | PED086 |
| ៨៧ | គ្រូបង្រៀនសំអាងកាយ | PED087 |
| ៨៨ | គ្រូបង្រៀនកែច្នៃអាហារ | PED088 |
| ៨៩ | គ្រូបង្រៀនអាហារនិងភេសជ្ជៈ | PED089 |
| ៩០ | គ្រូបង្រៀនអភិវឌ្ឍន៍កសិកម្ម | PED090 |
| ៩១ | គ្រូបង្រៀនកសិកម្មវៃឆ្លាត | PED091 |
| ៩២ | គ្រូបង្រៀនក្សេត្រសាស្ត្រ | PED092 |
| ៩៣ | គ្រូបង្រៀនជលផល | PED093 |
| ៩៤ | គ្រូបង្រៀនបសុវប្បកម្ម | PED094 |
| ៩៥ | គ្រូបង្រៀនមេកាត្រូនិក | PED095 |
| ឈ. មុខតំណែងបង្រៀននៅវិទ្យាល័យអប់រំពិសេស | | |
| ៩៦ | គ្រូបង្រៀនវិទ្យាល័យឯកទេសពិការសតិបញ្ញានិងអូទីស្សឹម | PED096 |
| ៩៧ | គ្រូបង្រៀនវិទ្យាល័យឯកទេសគថ្លង់ | PED097 |
| ៩៨ | គ្រូបង្រៀនវិទ្យាល័យឯកទេសពិការភ្នែក | PED098 |
| ៣. មុខតំណែងបង្រៀននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ | | |
| ៩៩ | គ្រូឧទ្ទេសអក្សរសាស្ត្រខ្មែរ | PED099 |
| ១០០ | គ្រូឧទ្ទេសគណិតវិទ្យា | PED100 |
| ១០១ | គ្រូឧទ្ទេសរូបវិទ្យា | PED101 |
| ១០២ | គ្រូឧទ្ទេសគីមីវិទ្យា | PED102 |
| ១០៣ | គ្រូឧទ្ទេសជីវវិទ្យា | PED103 |
| ១០៤ | គ្រូឧទ្ទេសផែនដីវិទ្យា | PED104 |
| ១០៥ | គ្រូឧទ្ទេសប្រវត្តិវិទ្យា | PED105 |
| ១០៦ | គ្រូឧទ្ទេសភូមិវិទ្យា | PED106 |

| ល.រ. | មុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន | លេខកូដ |
|---|---|---|
| ១០៧ | គ្រូឧទ្ទេសសីលធម៌ពលរដ្ឋវិជ្ជា | PED107 |
| ១០៨ | គ្រូឧទ្ទេសភាសាបរទេស | PED108 |
| ១០៩ | គ្រូឧទ្ទេសវិធីសាស្ត្របង្រៀន | PED109 |
| ១១០ | គ្រូឧទ្ទេសស្រាវជ្រាវការអប់រំ | PED110 |
| ១១១ | គ្រូឧទ្ទេសគរុកោសល្យ | PED111 |
| ១១២ | គ្រូឧទ្ទេសកម្មវិធីសិក្សា | PED112 |
| ១១៣ | គ្រូឧទ្ទេសចិត្តវិទ្យា | PED113 |
| ១១៤ | គ្រូឧទ្ទេសប្រឹក្សាគរុកោសល្យ | PED114 |
| ១១៥ | គ្រូឧទ្ទេសវង្វាយតម្លៃ | PED115 |
| ១១៦ | គ្រូឧទ្ទេសភាពជាអ្នកដឹកនាំនិងគ្រប់គ្រង | PED116 |
| ១១៧ | គ្រូឧទ្ទេសសិក្សាអន្តរជាតិនិងទំនាក់ទំនងអន្តរជាតិ | PED117 |
| ១១៨ | គ្រូឧទ្ទេសរដ្ឋបាលសាធារណៈ | PED118 |
| ១១៩ | គ្រូឧទ្ទេសគ្រប់គ្រងអប់រំ | PED119 |
| ១២០ | គ្រូឧទ្ទេសគ្រប់គ្រងព័ត៌មានវិទ្យា | PED120 |
| ១២១ | គ្រូឧទ្ទេសគ្រប់គ្រងបណ្ណាល័យ | PED121 |
| ១២២ | គ្រូឧទ្ទេសគ្រប់គ្រងបន្ទប់ពិសោធន៍ | PED122 |
| ១២៣ | គ្រូឧទ្ទេសអប់រំកុមារតូច | PED123 |
| ១២៤ | គ្រូឧទ្ទេសអប់រំកាយនិងកីឡា | PED124 |
| ១២៥ | គ្រូឧទ្ទេសអប់រំសុខភាពសាធារណៈ | PED125 |
| ១២៦ | គ្រូឧទ្ទេសអប់រំសិល្បៈ | PED126 |
| ១២៧ | គ្រូឧទ្ទេសព័ត៌មានវិទ្យាអប់រំ | PED127 |
| ១២៨ | គ្រូឧទ្ទេសវិស្វកម្មកុំព្យូទ័រ | PED128 |
| ១២៩ | គ្រូឧទ្ទេសអគ្គិសនី | PED129 |
| ១៣០ | គ្រូឧទ្ទេសអេឡិចត្រូនិក | PED130 |
| ១៣១ | គ្រូឧទ្ទេសមេកានិក | PED131 |
| ១៣២ | គ្រូឧទ្ទេសក្សេត្រសាស្ត្រ | PED132 |
| ១៣៣ | គ្រូឧទ្ទេសបសុវប្បកម្ម | PED133 |
| ១៣៤ | គ្រូឧទ្ទេសកែច្នៃអាហារ | PED134 |
| ១៣៥ | គ្រូឧទ្ទេសសេដ្ឋកិច្ច | PED135 |
| **ជ. មុខតំណែងបង្រៀននៅវិទ្យាស្ថានជាតិអប់រំពិសេស** | | |

| ល.រ. | មុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន | លេខកូដ |
|---|---|---|
| ១៣៦ | គ្រូឧទ្ទេសឯកទេសពិការសតិបញ្ញានិងអូទីស្សឹម | PED136 |
| ១៣៧ | គ្រូឧទ្ទេសឯកទេសគថ្លង់ | PED137 |
| ១៣៨ | គ្រូឧទ្ទេសឯកទេសពិការភ្នែក | PED138 |
| ឋ. មុខតំណែងបង្រៀននៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | | |
| ១៣៩ | គ្រូឧទ្ទេសវេជ្ជសាស្ត្រកីឡា | PED139 |
| ១៤០ | គ្រូឧទ្ទេសវិទ្យាសាស្ត្រកីឡា | PED140 |
| ១៤១ | គ្រូឧទ្ទេសអប់រំកាយ | PED141 |
| ១៤២ | គ្រូឧទ្ទេសបង្វឹកកីឡា | PED142 |
| ១៤៣ | គ្រូឧទ្ទេសគ្រប់គ្រងកីឡា | PED143 |

លេខកូដ PED001 មានន័យថា P=មុខតំណែងវិជ្ជាជីវៈ, ED=អប់រំ, 001= លេខរៀងលំដាប់មុខតំណែងវិជ្ជាជីវៈ។

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៦
ស្តីពីការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន

# ការពិពណ៌នាមុខតំណែងវិជ្ជាជីវៈគ្រូបង្រៀន

## ១- ការពិពណ៌នាមុខតំណែងទារកវប្បករ( លេខកូដ : PED001 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ទារកវប្បករ |
| ២- ឈ្មោះអង្គភាព | ( ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី ) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ( ត្រូវបំពេញដោយអង្គភាព ) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ( ត្រូវបំពេញដោយអង្គភាព ) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>- ដឹកនាំនិងគ្រប់គ្រងកម្មវិធីការអប់រំកុមារវ័យ១០០០ថ្ងៃដំបូងនៃជីវិត<br>- ដឹកនាំនិងគ្រប់គ្រងកិច្ចការទារកដ្ឋាន និងកម្មវិធីការអប់រំមាតាបិតា<br>- អភិវឌ្ឍវិធីសាស្ត្រនិងឯកសារពាក់ព័ន្ធនឹងការអប់រំកុមារវ័យដំបូង<br>- អភិវឌ្ឍវិធីសាស្ត្រនិងឯកសារកិច្ចការទារកដ្ឋាននិងកម្មវិធីការអប់រំមាតាបិតា<br>- អភិវឌ្ឍក្របខ័ណ្ឌគតិយុត្តស្តីពីការបង្កើត ការទទួលស្គាល់ ការបិទ ការគ្រប់គ្រងទារកដ្ឋាន និងកម្មវិធីអប់រំមាតាបិតា<br>- កសាងផែនទីសិក្សានិងរៀបចំកម្មវិធីអន្តរាគមន៍ទាន់ពេលវេលាចំពោះកុមារតូចងាយរងគ្រោះ កុមាររងគ្រោះ ការផ្តល់សេវាទារកដ្ឋាន និងការអប់រំមាតាបិតា<br>- រៀបចំបណ្តុះបណ្តាលទាក់ទងនឹងសុខភាពផ្លូវភេទនិងការបង្កកំណើត<br>- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេសៈ ជីវៈវិទ្យា សុខភាពសាធារណៈ ឬជំនាញឯកទេសពាក់ព័ន្ធ |

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងច្បាស់លាស់ផ្នែកសុខភាពទារកនិងមាតា<br>- ចេះរៀបចំផែនការសកម្មភាពឬសិក្ខាសាលាសម្រាប់ណែនាំសុខភាព<br>- មានចំណេះដឹងផ្នែកសុខភាពបន្តពូជនិងការថែទាំសុខភាពផ្លូវភេទ<br>- ចុះផ្ទាល់ជាមួយសហគមន៍ ដើម្បីណែនាំមាតាក្នុងកិច្ចការថែទាំទារក<br>- មានសមត្ថភាពសម្របសម្រួលនិងដោះស្រាយបញ្ហាស្របតាមតួនាទីនិងភារកិច្ចរបស់ខ្លួន<br>- ពិនិត្យ តាមដានសុខភាពមាតា និងទារកក្នុងសហគមន៍<br>- ចេះប្រើប្រាស់កុំព្យូទ័រនិងភាសាបរទេស<br>- មានសមត្ថភាពដឹកនាំសកម្មភាពផ្សព្វផ្សាយអំពីសារៈសំខាន់នៃការថែទាំកុមារតូច<br>- ចេះរៀបចំកាលវិភាគ ផែនការ ថែទាំកូនចៅដល់មាតាក្នុងសហគមន៍<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្ដីភាពចំពោះការចូលរួមអភិវឌ្ឍវិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ មិនសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្ដី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ២- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនមត្តេយ្យសិក្សា(លេខកូដ : PED002)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនមត្តេយ្យសិក្សា |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- បង្រៀន បណ្តុះបណ្តាល និងតម្រង់ទិសវិជ្ជាជីវៈទៅកាន់កុមារ<br>- ផ្តល់ការបណ្តុះបណ្តាល អប់រំបំណិនជីវិត ចរិយាធម៌ និងបទពិសោធដល់កុមារ<br>- ចែករំលែកនិងតម្រង់ទិសវិជ្ជាជីវៈដល់កុមារ<br>- ស្រាវជ្រាវវិធីសាស្ត្របង្រៀនយោងតាមខ្លឹមសារនៃគ្រូសតវត្សទី២១<br>- រៀបចំនិងដឹកនាំសិស្សធ្វើគម្រោង និងបង្កើតស្នាដៃផ្សេងៗ<br>- ផ្តល់ទស្សនាទានកែលម្អលើរបាយការណ៍ និងស្នាដៃសិស្ស<br>- ចូលរួមត្រួតពិនិត្យផែនការសាលារៀន<br>- គោរពនិងអនុវត្តតាមតួនាទី ភារកិច្ចដូចមានចែងក្នុងនិយាមប្រើប្រាស់បុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ មត្តេយ្យ ឬសញ្ញាបត្រសមមូល |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |

<table>
<tr>
<td rowspan="2">៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព)</td>
<td>ចំណេះដឹងនិងជំនាញ៖<br>- ចេះរៀបចំផែនការបង្រៀននិងរដ្ឋបាលគ្រូ(កិច្ចតែងការបង្រៀន រដ្ឋបាលថ្នាក់រៀន និងឯកសារពាក់ព័ន្ធ)<br>- ចេះរៀបចំផែនការប្រចាំឆ្នាំ ផែនការ៣ឆ្នាំ និងផែនការ៥ឆ្នាំ យោងតាមតម្រូវការសាលារៀន<br>- ចេះបង្រៀន ទទួលបន្ទុកថ្នាក់ រៀបចំកិច្ចការរដ្ឋបាលសាលារៀន និងទទួលបន្ទុកមន្ទីរពិសោធន៍ យោងតាមតម្រូវការសាលារៀន<br>- ចូលរួមសកម្មភាពសង្គម ការប្រជុំ សិក្ខាសាលាយោងតាមឧទ្ទេសនាម បង្គាប់ការ និងលិខិតអញ្ជើញផ្សេងទៀត<br>- មានទំនាក់ទំនងល្អជាមួយសហគមន៍ដើម្បីការអភិវឌ្ឍសាលារៀន<br>- ចេះដឹកនាំសិស្សានុសិស្សសិក្សាបែបគម្រោង<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។</td>
</tr>
<tr>
<td>ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍវិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ មិនសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាព និងវិស័យអប់រំ។</td>
</tr>
</table>

## ៣- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសប្រឹក្សាគរុកោសល្យអប់រំកុមារតូច( លេខកូដ : PED003 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនមត្តេយ្យសិក្សាប្រឹក្សាគរុកោសល្យអប់រំកុមារតូច |
| ២- ឈ្មោះអង្គភាព | ( ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី ) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ( ត្រូវបំពេញដោយអង្គភាព ) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖( ត្រូវបំពេញដោយអង្គភាព ) |
| ៥- តួនាទីភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- ផ្តល់ការប្រឹក្សា និងណែនាំគ្រូបង្រៀនផ្សេងទាក់ទងវិធីសាស្រ្តបង្រៀន និងគ្រប់គ្រងថ្នាក់អប់រំកុមារតូច ដើម្បីជានាបរិយាកាសសិក្សាដែលសមស្របសម្រាប់កុមារតូច<br>- ជួយគ្រូបង្រៀនក្នុងការរៀបចំផែនការមេរៀននិងសកម្មភាពអប់រំដើម្បីអភិវឌ្ឍជំនាញសង្គម អារម្មណ៍ និងកាយវិការរបស់កុមារតូច<br>- ជួយដោះស្រាយបញ្ហានិងផ្តល់ការណែនាំដល់គ្រូបង្រៀនទាក់ទងការគ្រប់គ្រងថ្នាក់ និងការបង្រៀនកុមារតូច<br>- ចូលរួមវាយតម្លៃសមត្ថភាពសិក្សារបស់កុមារតូចដើម្បីផ្តល់យោបល់ និងណែនាំគ្រូក្នុងការកែលម្អការបង្រៀន<br>- ចូលរួមសកម្មភាពផ្សេងៗដើម្បីអភិវឌ្ឍន៍សមត្ថភាពខ្លួនឯងលើវិធីសាស្រ្តប្រឹក្សាគរុកោសល្យ និងអប់រំកុមារតូចដើម្បីប្រើប្រាស់ក្នុងការប្រឹក្សាគ្រូ<br>- ចូលរួមត្រួតពិនិត្យផែនការសាលារៀន<br>- គោរពនិងអនុវត្តតាមតួនាទីភារកិច្ចដូចមានចែងក្នុងនិយាមប្រើប្រាស់បុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ ចិត្តគរុកោសល្យ ចិត្តវិទ្យា ឬជំនាញឯកទេសពាក់ព័ន្ធនឹងការអប់រំកុមារតូច |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | ប្រឡងជាប់ជាស្ថាពរនិងក្រោយពេលបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ |

<table>
<tr>
<td rowspan="2">៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព)</td>
<td>ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងច្បាស់លាស់លើការអប់រំកុមារតូច និងចិត្តវិទ្យាកុមារដើម្បីប្រើប្រាស់ក្នុងការប្រឹក្សា និងណែនាំគ្រូបង្រៀន<br>- មានជំនាញប្រឹក្សាយោបល់និងទំនាក់ទំនងល្អដើម្បីធ្វើការជាមួយគ្រូផ្សេង និងគណៈគ្រប់គ្រងសាលា<br>- មានជំនាញវាយតម្លៃអភិវឌ្ឍន៍ភាពផ្ទាល់ខ្លួននិងសមត្ថភាពសិស្ស ដើម្បីផ្តល់យោបល់ និងកែលម្អការបង្រៀនរបស់គ្រូ<br>- មានសមត្ថភាពធ្វើបច្ចុប្បន្នកម្មចំណេះដឹងថ្មីៗក្នុងវិធីសាស្រ្តប្រឹក្សាគរុកោសល្យ និងអប់រំកុមារតូច<br>- មានចំណេះដឹងលើវិធីសាស្រ្តបង្រៀនថ្មីៗ<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។</td>
</tr>
<tr>
<td>ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ មិនសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។</td>
</tr>
</table>

## ៤- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសពិការសតិបញ្ញានិងអូទីស្សឹម ( **លេខកូដ** : PED004 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសពិការសតិបញ្ញានិងអូទីស្សឹម |
| ២- ឈ្មោះអង្គភាព | ( ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី ) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ( ត្រូវបំពេញដោយអង្គភាព ) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ ( ត្រូវបំពេញដោយអង្គភាព ) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- បង្រៀននិងចែករំលែកសកម្មភាពអប់រំដល់កុមារពិការភាពសតិបញ្ញា និងអូទីស្សឹមដោយប្រើវិធីសាស្ត្រពិសេស និងបច្ចេកទេសសមស្របសម្រាប់កុមារតូចផ្សេងៗគ្នា
- ប្រមូលស្ថិតិសិស្សមានពិការភាពខ្សោយសតិបញ្ញានិងអូទីស្សឹមនៅតាមសហគមន៍
- កំណត់អត្តសញ្ញាណបឋមកុមារមានពិការភាពនិងផ្សព្វផ្សាយឱ្យយល់ដឹងពីពិការភាពដល់ប្រជាសហគមន៍
- ធ្វើផែនទីខ្នងផ្ទះនិងផែនទីសិក្សាកុមារមានពិការភាពឱ្យបានត្រឹមត្រូវ
- រៀបចំថ្នាក់រៀន ដាក់ស្លាកសញ្ញា កិច្ចតែងការបង្រៀននិងរៀន សៀវភៅបញ្ជីហៅឈ្មោះ ពិន្ទុសិស្ស និងរដ្ឋបាលថ្នាក់រៀន
- ធ្វើរបាយការណ៍ស្តីពីការបង្រៀនថ្នាក់អប់រំពិសេសនិងថ្នាក់សមាហរណកម្ម រួចបញ្ជូនតាមឋានានុក្រម
- បំពេញកម្រងសំណួរប្រមូលព័ត៌មានកម្មវិធីអប់រំពិសេស ( ផ្នែកសតិបញ្ញា និងអូទីស្សឹម ) តាមពេលវេលាកំណត់ រួចបញ្ជូនតាមឋានានុក្រម
- ចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលានានា
- ចេះផលិតសម្ភារៈសិក្សាទៅតាមចរិតលក្ខណសម្បត្តិរបស់កុមារមានពិការភាពសតិបញ្ញា និងអូទីស្សឹម ឯកសារផ្សេងៗ និងរៀបចំបញ្ជីវាយតម្លៃសម្បទារបស់កុមារមានពិការភាព
- យល់ដឹងពីការប្រាស្រ័យទាក់ទងពីតម្រូវការពិសេស និងចូលចិត្តកុមារមានពិការភាព ( មានបេះដូង )
- មានសមត្ថភាពរៀបចំផែនការជួយជាបុគ្គល បង្រៀនសិស្សមានពិការភាព និងធ្វើកិច្ចតែងការបង្រៀន
- មានសមត្ថភាពវាស់កម្រិតបញ្ញា (IQ) និងវិធីក្នុងការវាយតម្លៃឱ្យសិស្សឡើងថ្នាក់
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
|---|---|
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈបរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ អប់រំពិសេស ជំនាញបង្រៀនសិស្សគថ្លង់ ពិការភ្នែក ឬពិការសតិបញ្ញា និងអូទីស្សឹម ឬជំនាញពាក់ព័ន្ធ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងច្បាស់លាស់លើ អប់រំសិស្សមានពិការភាព ខ្សោយសតិបញ្ញា និងអូទីស្សឹម<br>- ចេះប្រមូលស្ថិតិសិស្សមានពិការភាពខ្សោយសតិបញ្ញា និងអូទីស្សឹម<br>- ចេះកំណត់អត្តសញ្ញាណបឋមកុមារមានពិការភាព និងផ្សព្វផ្សាយឱ្យយល់ដឹងពីពិការភាព<br>- ចេះរៀបចំរដ្ឋបាលថ្នាក់រៀន សៀវភៅបញ្ជីហៅឈ្មោះ បញ្ជីពិន្ទុសិស្ស ដាក់ស្លាកសញ្ញាថ្នាក់រៀន កិច្ចតែងការបង្រៀន<br>- ចេះធ្វើរបាយការណ៍ស្តីពីការបង្រៀនថ្នាក់អប់រំពិសេសនិងថ្នាក់សមាហរណកម្ម<br>- ចេះផលិតសម្ភារៈសិក្សាទៅតាមចរិតលក្ខណសម្បត្តិរបស់កុមារមានពិការភាពសតិបញ្ញា និងអូទីស្សឹម ឯកសារផ្សេងៗ និងរៀបចំបញ្ជីវាយតម្លៃសម្បទារបស់កុមារមានពិការភាព<br>- មានសមត្ថភាពយល់ដឹងពីការប្រាស្រ័យទាក់ទងពីតម្រូវការពិសេស និងចូលចិត្តកុមារមានពិការភាព (មានបេះដូង )<br>- មានសមត្ថភាពរៀបចំផែនការជួយជាបុគ្គល បង្រៀនសិស្សមានពិការភាព និងធ្វើកិច្ចតែងការបង្រៀន<br>- មានសមត្ថភាពវាស់កម្រិតបញ្ញា (IQ) និងវិធីក្នុងការវាយតម្លៃឱ្យសិស្សឡើងថ្នាក់<br>- មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រកម្រិតមូលដ្ឋាន<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ ជៀសវាងការសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ៥- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសគថ្លង់ (លេខកូដ : PED005)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសគថ្លង់ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- បង្រៀនកុមារគថ្លង់ដោយប្រើវិធីសាស្ត្រពិសេស និងឧបករណ៍សមស្របសម្រាប់កុមារគថ្លង់<br>- វាយតម្លៃសមត្ថភាពសិក្សារបស់កុមារគថ្លង់ ដើម្បីកែលម្អកម្មវិធីសាស្ត្របង្រៀន<br>- មើលថែទាំ ងូតទឹក ស្លៀកពាក់ ហូបចុក និងបត់ជើងតូច ធំ ក្នុងម៉ោងបង្រៀន<br>- រៀបចំខ្លឹមសារបង្រៀន និងវិធីសាស្ត្របង្រៀនដោយប្រើប្រាស់ភាសាសញ្ញា និងសញ្ញាក្នុងការបង្រៀននិងរៀន<br>- ត្រួតពិនិត្យនិងជួសជុលឧបករណ៍ជំនួយការស្តាប់សម្រាប់កុមារគថ្លង់<br>- ចូលរួមគ្រប់សកម្មភាពក្នុងការពិនិត្យត្រចៀកជាមួយគ្រូពេទ្យជំនាញ<br>- បង្រៀនភាសាសញ្ញាដល់មាតាបិតា ឬអាណាព្យាបាលសិស្សដើម្បីជួយជំរុញការងាររៀនសូត្រនៅផ្ទះ<br>- បង្កើតសម្ភារៈឧបទេស និមិត្តសញ្ញា និងសម្ភារៈផុសសម្រាប់បង្រៀននិងរៀន<br>- បង្រៀនពីប្រមាណវិធីដើម្បីគណនាលើក្បាច់<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ អប់រំពិសេស ជំនាញបង្រៀនសិស្សគថ្លង់ ពិការភ្នែក ឬពិការសតិបញ្ញា និងអូទីស្សឹម ឬជំនាញពាក់ព័ន្ធ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងអំពីការអប់រំកុមារពិការរាងកាយ និងគថ្លង់<br>- មានចំណេះដឹងអំពីការអភិវឌ្ឍកុមារតូចក្នុងផ្នែកកាយវិការ ភាសា សង្គម បញ្ញា និងអារម្មណ៍<br>- មានចំណេះដឹងពីឧបករណ៍អនុវត្តសិក្សាសម្រាប់កុមារដែលមានគថ្លង់<br>- មានជំនាញក្នុងការកត់ត្រានិងតាមដាន សមត្ថភាព និងការរីកចម្រើនរបស់កុមារគថ្លង់<br>- មានជំនាញទំនាក់ទំនងល្អជាមួយកុមារ អ្នកអាណាព្យាបាល និងសហគមន៍<br>- មានចំណេះដឹងអំពីសុវត្ថិភាព និងអនាម័យក្នុងការងារជាមួយកុមារពិការរាងកាយ<br>- ចេះប្រឹក្សាយោបល់ទាក់ទងការបង្រៀនកុមារគថ្លង់ដល់គ្រូមត្តេយ្យផ្សេងៗទៀត<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្ដីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ ជៀសវាងការសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្ដី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាព និងវិស័យអប់រំ។ |

**៦- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសពិការភ្នែក** ( **លេខកូដ** : PED006 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនមត្តេយ្យសិក្សាឯកទេសពិការភ្នែក |
| ២- ឈ្មោះអង្គភាព | ( ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី ) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ( ត្រូវបំពេញដោយអង្គភាព ) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន ៖ ( ត្រូវបំពេញដោយអង្គភាព ) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង ៖

- មើលថែទាំ ងូតទឹក ស្លៀកពាក់ ហូបចុក និងបត់ជើងតូច ធំ ក្នុងម៉ោងបង្រៀន
- អប់រំ សម្របសម្រួល និងគាំទ្រកុមារមត្តេយ្យដែលមានបញ្ហាពិការភ្នែកដើម្បីអភិវឌ្ឍន៍ជំនាញដំបូងៗ
- បង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងសមស្របសម្រាប់កុមារដែលមានការបាត់បង់ឬកង្វះចក្ខុវិស័យ
- រៀបចំខ្លឹមសារបង្រៀននិងវិធីសាស្ត្របង្រៀនដោយប្រើប្រាស់ភាសាសញ្ញា និងសញ្ញាក្នុងការបង្រៀននិងរៀន ប្រើប្រាស់វិធីពន្យល់ន័យពាក្យអរូបី បញ្ញត្តិថ្មី និងបត់បែនតាមប្រភេទពិការភាពក្នុងថ្នាក់នីមួយៗ
- ប្រមូលសិស្សចូលរៀនវិញក្រោយពីចេញលេង
- ត្រួតពិនិត្យ ជួសជុលឧបករណ៍ជំនួយការស្តាប់ និងឧបករណ៍ជំនួយការមើលជាប្រចាំ
- ត្រួតពិនិត្យតាមដានសេវាសុខភាព បញ្ជូនសិស្សទៅមន្ទីរពេទ្យតាមប្រភេទពិការ តាមថែទាំ និងបកប្រែ
- បង្រៀនវិធីសាស្ត្រសម្រាប់នាំផ្លូវជនពិការភ្នែក
- ចូលរួមគ្រប់សកម្មភាពក្នុងការពិនិត្យត្រចៀក ពិនិត្យគំហើញជាមួយគ្រូពេទ្យជំនាញ
- បង្រៀនភាសាសញ្ញាដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដើម្បីជួយជំរុញការងាររៀនសូត្រនៅផ្ទះ
- បង្កើតសម្ភារៈឧបទេស និមិត្តសញ្ញា និងសម្ភារៈផុសសម្រាប់បង្រៀននិងរៀន
- បង្រៀនពីប្រមាណវិធីដើម្បីគណនាលើក្បាច់
- បង្រៀនអក្សរប្រៃយ៍(អក្សរស្ទាប) នៅលើស្លេត និងស្លៃឡាស់
- បង្រៀនសិស្សខ្សោយគំហើញដោយប្រើអក្សរធំៗ រូបភាពដិត និងក្តារទម្រ
- បកប្រែភាសាសញ្ញាដល់ជនគថ្លង់ដែលមានធុរៈ ប្រឡងសញ្ញាបត្រ និងពិធីផ្សេងៗ
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង (គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
|---|---|
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ (ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈបរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ អប់រំពិសេស ជំនាញបង្រៀនសិស្សគថ្លង់ ពិការភ្នែក ឬពិការសតិបញ្ញា និងអូទីស្សឹម ឬជំនាញឯកទេសពាក់ព័ន្ធ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ (អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងច្បាស់លាស់អំពីការអប់រំកុមារពិការភ្នែក និងលក្ខណៈពិសេសនៃពិការភ្នែក<br>- ចេះរៀបចំខ្លឹមសារបង្រៀននិងវិធីសាស្ត្របង្រៀនដោយប្រើប្រាស់ភាសាសញ្ញានិងសញ្ញាក្នុងការបង្រៀននិងរៀនកុមារពិការភ្នែក<br>- ដឹងអំពីការអភិវឌ្ឍនិងតម្រូវការពិសេសផ្សេងៗរបស់កុមារពិការភ្នែក<br>- ចេះត្រួតពិនិត្យ ជួសជុលឧបករណ៍ជំនួយការស្តាប់ និងឧបករណ៍ជំនួយការមើលជាប្រចាំ<br>- មានជំនាញបង្រៀនវិធីសាស្ត្រសម្រាប់កុមារពិការភ្នែក<br>- ចេះបង្រៀនភាសាសញ្ញាដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដើម្បីជួយជំរុញការងាររៀនសូត្រនៅផ្ទះ<br>- ចេះបង្កើតសម្ភារៈឧបទេស និមិត្តសញ្ញា និងសម្ភារៈផុសសម្រាប់បង្រៀននិងរៀន<br>- ចេះបង្រៀនពីប្រមាណវិធីដើម្បីគណនាលើក្បាច់<br>- ចេះបង្រៀនអក្សរប្រៃយ៍ (អក្សរស្ទាប) នៅលើស្លេត និងស្លែឡាស់<br>- មានទំនាក់ទំនងសង្គមនិងជំរុញការចូលរួមក្នុងសកម្មភាពនានា<br>- ចេះធ្វើការសហការជាមួយអ្នកឯកទេសនានាដូចជាគ្រូពេទ្យចិត្តសាស្ត្រ អ្នកសង្គមកិច្ច និងអាណាព្យាបាល<br>- ចេះរក្សាឯកសារនិងរបាយការណ៍ត្រឹមត្រូវ<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ ជៀសវាងការសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ៧- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សា( លេខកូដ : PED007 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សា |
| ២- ឈ្មោះអង្គភាព | ( ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី ) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ( ត្រូវបំពេញដោយអង្គភាព ) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖( ត្រូវបំពេញដោយអង្គភាព ) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- បណ្តុះបណ្តាលនិងតម្រង់ទិសវិជ្ជាជីវៈទៅកាន់កុមារ<br>- ផ្តល់ការបណ្តុះបណ្តាល អប់រំបំណិនជីវិត ចរិយាធម៌ និងបទពិសោធដល់កុមារ<br>- ចែករំលែកនិងតម្រង់ទិសវិជ្ជាជីវៈដល់កុមារ<br>- ស្រាវជ្រាវវិធីសាស្ត្របង្រៀនយោងតាមខ្លឹមសារនៃគ្រូសតវត្សទី២១<br>- រៀបចំនិងដឹកនាំសិស្សរៀបចំគម្រោងនិងស្នាដៃផ្សេងៗ<br>- ផ្តល់ទស្សនទានកែលម្អលើរបាយការណ៍និងស្នាដៃសិស្ស<br>- ចូលរួមត្រួតពិនិត្យផែនការសាលារៀន<br>- គោរពនិងអនុវត្តតាមតួនាទីភារកិច្ចដូចមានចែងក្នុងនិយាមប្រើប្រាស់បុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ បឋមសិក្សា ឬសញ្ញាបត្រសមមូល |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- ចេះរៀបចំផែនការបង្រៀននិងរដ្ឋបាលគ្រូ(កិច្ចតែងការបង្រៀន រដ្ឋបាលថ្នាក់រៀន និងឯកសារពាក់ព័ន្ធ)<br>- ចេះរៀបចំផែនការប្រចាំឆ្នាំ ផែនការ៣ឆ្នាំ និងផែនការ៥ឆ្នាំ យោងតាមតម្រូវការសាលារៀន<br>- ចេះរៀបចំកិច្ចការរដ្ឋបាលសាលារៀននិងទទួលបន្ទុកមន្ទីរពិសោធន៍យោងតាមតម្រូវការសាលារៀន<br>- មានទំនាក់ទំនងសហគមន៍ដើម្បីការអភិវឌ្ឍសាលារៀន<br>- ចេះដឹកនាំសិស្សានុសិស្សសិក្សាបែបគម្រោង<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ មិនសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ៨- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សាភាសាបរទេស(លេខកូដ : PED008)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សាភាសាបរទេស |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- បង្រៀនភាសាបរទេសតាមកម្មវិធីសិក្សារដ្ឋដើម្បីអភិវឌ្ឍន៍ជំនាញស្តាប់ និយាយ អាន និងសរសេរដល់កុមារ<br>- រៀបចំផែនការមេរៀនឱ្យសមស្របនឹងកម្រិតអាយុនិងសមត្ថភាពកុមារ<br>- ប្រើសម្ភារៈបង្រៀន ឧបករណ៍បច្ចេកវិទ្យា និងសកម្មភាពលើកទឹកចិត្តដើម្បីធ្វើឱ្យកុមាររៀនមានភាពសប្បាយរីករាយនិងសកម្ម<br>- វាយតម្លៃការសិក្សារបស់កុមារតាមលក្ខណៈស្តង់ដា កត់ត្រាពិន្ទុ និងផ្តល់មតិត្រឡប់អំពីការរីកចម្រើនរបស់សិស្សដល់អាណាព្យាបាលជាទៀងទាត់<br>- ផ្តល់ជំនួយបន្ថែមដល់កុមារដែលមានតម្រូវការពិសេស និងលើកទឹកចិត្តសិស្សដែលមានសមត្ថភាពឱ្យកាន់តែពូកែ<br>- រៀបចំវិន័យថ្នាក់រៀននិងចៀសវាងស្ថានភាពដែលធ្វើឱ្យកុមារខ្លាច<br>- សហការជាមួយគ្រូនិងគណៈគ្រប់គ្រងសាលារៀនក្នុងការរៀបចំសកម្មភាពសាលា និងសកម្មភាពសិក្សាក្រៅថ្នាក់<br>- ធ្វើទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មានជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលកុមារអំពីការរៀន និងវឌ្ឍនភាពរបស់កុមារ<br>- ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីអភិវឌ្ឍន៍សមត្ថភាពខ្លួនឯង<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ ភាសាបរទេសផ្សេងៗស្របតាមមុខតំណែង |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | ប្រឡងជាប់ជាស្ថាពរនិងក្រោយពេលបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងគ្រប់គ្រាន់អំពីភាសាបរទេសដែលបង្រៀន( ស្តាប់ និយាយ អាន សរសេរ ) និងការប្រើពាក្យសព្ទនិងវេយ្យាករណ៍ត្រឹមត្រូវ<br>- មានចំណេះដឹងអំពីកម្មវិធីសិក្សារដ្ឋ និងគោលការណ៍អប់រំជាតិទាក់ទងនឹងការបង្រៀនភាសាបរទេសនៅបឋមសិក្សា<br>- មានជំនាញរៀបចំផែនការមេរៀននិងរចនាសកម្មភាពបង្រៀនដែលសមស្របតាមកម្រិតអាយុ និងសមត្ថភាពកុមារ<br>- មានសមត្ថភាពប្រើឧបករណ៍បច្ចេកវិទ្យាដែលគាំទ្រការបង្រៀន<br>- មានជំនាញគ្រប់គ្រងថ្នាក់រៀន បង្កើតបរិយាកាសដែលមានវិន័យ ទំនាក់ទំនងដ៏ល្អ និងគោរពគ្នាទៅវិញទៅមក<br>- មានជំនាញទំនាក់ទំនងល្អជាមួយកុមារ មាតាបិតា/អ្នកអាណាព្យាបាល និងមិត្តរួមការងារ<br>- មានសមត្ថភាពវាយតម្លៃលទ្ធផលសិក្សារបស់កុមារ និងកត់ត្រាលទ្ធផលបានយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា<br>- មានការស្ម័គ្រចិត្តចូលរួមធ្វើការអភិវឌ្ឍវិជ្ជាជីវៈដោយខ្លួនឯង និងការសហការជាក្រុមក្នុងសាលា<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្ដីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ មិនសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ៩- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សាបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(លេខកូដ : PED009)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សា បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- បង្រៀននិងបណ្តុះបណ្តាលចំណេះដឹងតម្រង់ទិសវិជ្ជាជីវៈបច្ចេកទេសព័ត៌មាននិងទូរគមនាគមន៍(ICT)ទៅកាន់កុមារ<br>- ដឹកនាំនិងអនុវត្តផ្ទាល់បច្ចេកទេសព័ត៌មាននិងទូរគមនាគមន៍(ICT)ដំបូងសម្រាប់កុមារ<br>- ប្រចាំការនៅសាលាដើម្បីជួយដោះស្រាយបញ្ហាបច្ចេកទេសព័ត៌មាននិងទូរគមនាគមន៍(ICT) ដល់កុមារ<br>- រៀបចំកម្មវិធីកំសាន្តនិងបណ្តុះគំនិតអនុវត្តបច្ចេកទេសព័ត៌មាននិងទូរគមនាគមន៍(ICT)<br>- ផ្តល់ការបណ្តុះបណ្តាល អប់រំបំណិនជីវិត ចរិយាធម៌ និងបទពិសោធដល់កុមារ<br>- ចែករំលែកនិងតម្រង់ទិសវិជ្ជាជីវៈដល់កុមារ<br>- ស្រាវជ្រាវវិធីសាស្ត្របង្រៀនយោងតាមខ្លឹមសារនៃគ្រូសតវត្សទី២១<br>- រៀបចំនិងដឹកនាំសិស្សរៀបចំគម្រោងនិងស្នាដៃផ្សេងៗ<br>- ផ្តល់ទស្សនទានកែលម្អលើរបាយការណ៍និងស្នាដៃសិស្ស<br>- ចូលរួមត្រួតពិនិត្យផែនការសាលារៀន<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ ព័ត៌មានវិទ្យា ទូរគមនាគមន៍ ឬជំនាញឯកទេសពាក់ព័ន្ធ |

| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |
| --- | --- |
| | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងច្បាស់លាស់ផ្នែកបច្ចេកទេសព័ត៌មាននិងទូរគមនាគមន៍(ICT)<br>- ចេះរៀបចំផែនការបង្រៀននិងរដ្ឋបាលគ្រូ(កិច្ចតែងការបង្រៀន រដ្ឋបាលថ្នាក់រៀន និងឯកសារពាក់ព័ន្ធ)<br>- ចេះរៀបចំផែនការប្រចាំឆ្នាំ ផែនការ៣ឆ្នាំ និងផែនការ៥ឆ្នាំ យោងតាមតម្រូវការសាលារៀន<br>- ចេះរៀបចំកិច្ចការរដ្ឋបាលសាលារៀននិងទទួលបន្ទុកមន្ទីរពិសោធន៍ យោងតាមតម្រូវការសាលារៀន<br>- មានទំនាក់ទំនងសហគមន៍ដើម្បីការអភិវឌ្ឍសាលារៀន<br>- មានសមត្ថភាពក្នុងការដឹកនាំសិស្សានុសិស្សសិក្សាបែបគម្រោង<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្ដីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ មិនសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្ដី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ១០- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សាប្រឹក្សាតាមសាលារៀន (លេខកូដ : PED010)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សាប្រឹក្សាតាមសាលារៀន |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- ចូលរួម គាំទ្រ ការអនុវត្តកម្មវិធីសិក្សាប្រឹក្សាអាជីព តម្រង់ទិសវិជ្ជាជីវៈ និងគន្លងសិក្សារបស់សិស្ស<br>- ផ្តល់សេវាប្រឹក្សាអាជីព និងការអប់រំ ការជ្រើសរើសគន្លងសិក្សា និងការជ្រើសរើសកម្មវិធីសិក្សាឱ្យស្របតាមឧបនិស្ស័យនិងកត្តាធម្មជាតិរបស់សិស្ស<br>- ទំនាក់ទំនងជាមួយសហគមន៍ សហគ្រាសឯកជន និងវាគ្មិនសំខាន់ រៀបចំកម្មវិធីតម្រង់ទិសនានានៅតាមភូមិសិក្សា<br>- ទំនាក់ទំនងជាមួយសាកលវិទ្យាល័យក្នុងប្រទេសនិងអន្តរជាតិ ដើម្បីស្នើសុំការផ្តល់បទបង្ហាញ អំពីការជ្រើសរើសឯកទេស និងការត្រៀមខ្លួនជាស្រេចសម្រាប់ការរៀននៅថ្នាក់ឧត្តមសិក្សា<br>- វាយតម្លៃជាប្រចាំទៅលើសមត្ថភាពសិស្ស ផ្តល់ការប្រឹក្សាក្នុងការជ្រើសរើសជំនាញ និងកែប្រែគន្លងសិក្សាឱ្យទាន់ពេលវេលា<br>- បង្កើតផែនការសកម្មភាពសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ សីលធម៌ និងវប្បធម៌ទូទៅក្នុងបរិស្ថានការងារ<br>- អនុវត្តស្តង់ដាក្រមសីលធម៌ និងគោលការណ៍វិជ្ជាជីវៈនៅតាមសាលារៀន<br>- ស្នង់មតិនិងបច្ចុប្បន្នកម្មទិន្នន័យជាប្រចាំសម្រាប់អង្គភាព ក្រសួងអប់រំ យុវជន និងកីឡា ជាមូលដ្ឋានសម្រាប់ការរៀបចំផែនការអាទិភាព និងការធ្វើផែនការគន្លងសិក្សា<br>- រៀបចំកិច្ចប្រជុំទាក់ទងនឹងសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ការបែងចែកថ្នាក់ និងការរៀបចំគន្លងសិក្សានៅតាមភូមិសិក្សា<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ ចិត្តវិទ្យាអប់រំ គ្រប់គ្រងអប់រំ សង្គមវិទ្យា ឬជំនាញឯកទេសពាក់ព័ន្ធ |

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងអំពីព័ត៌មានទីផ្សារការងារនិងប្រព័ន្ធអប់រំកម្ពុជា និងយល់ដឹងអំពីឥទ្ធិពលផ្នែកវប្បធម៌ សង្គម និងនយោបាយលើដំណើរការវិស័យអប់រំ<br>- យល់ដឹងអំពីគោលការណ៍ក្រមសីលធម៌វិជ្ជាជីវៈជាគ្រូប្រឹក្សាតាមសាលារៀន និងទិដ្ឋភាពគោលការណ៍ច្បាប់ទាក់ទងនឹងតួនាទីរបស់គ្រូប្រឹក្សាតាមសាលារៀន<br>- យល់ដឹងអំពីទ្រឹស្តីអភិវឌ្ឍន៍និងទ្រឹស្តីនានាទាក់ទងនឹងការសិក្សា<br>- ស្គាល់បុគ្គលិកលក្ខណៈរបស់សិស្សនិងរបៀបរៀនខុសៗគ្នារបស់សិស្ស<br>- យល់ដឹងអំពីបច្ចេកទេសគាំទ្រសិស្សដែលមានតម្រូវការពិសេស<br>- ប៉ិនប្រសប់ក្នុងការប្រើប្រាស់ទ្រឹស្តីប្រឹក្សាអាជីព និងបច្ចេកទេសក្នុងកាលៈទេសៈផ្សេងៗ ដូចជាក្នុងពេលផ្តល់ប្រឹក្សាទល់មុខម្នាក់ទល់ម្នាក់ ជាក្រុមតូចៗ និងក្នុងពេលបង្រៀនម៉ោងមគ្គុទ្ទេសក៍ក្នុងថ្នាក់ជាដើម<br>- យល់ដឹងអំពីឱកាសការងារក្នុងសហគមន៍ ក្នុងប្រទេស និងទំនោរការងារនាពេលអនាគត<br>- យល់ដឹងអំពីឱកាសអប់រំបន្ត និងទំនោរនានាក្នុងវិស័យអប់រំ<br>- មានមូលដ្ឋានព័ត៌មានអំពីការអប់រំ ការសិក្សា អាជីព មុខរបរ តម្រូវការបុគ្គលនិងសង្គម ដើម្បីលើកកម្ពស់ការអភិវឌ្ឍគុណសម្បទារបស់សិស្ស<br>- មានសមត្ថភាពរៀបចំសិក្ខាសាលា និងដឹកនាំ រៀបចំ សម្របសម្រួលសកម្មភាពមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា<br>- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា<br>- មានចំណេះដឹងផ្នែកគ្រប់គ្រងអប់រំ គន្លងអាជីព និងគន្លងសិក្សារបស់សិស្ស<br>- មានចំណេះដឹងផ្នែកចិត្តវិទ្យាអប់រំ |

| | |
|---|---|
| | - មានជំនាញមូលដ្ឋានក្នុងការសរសេររបាយការណ៍ និងការសិក្សាស្រាវជ្រាវ<br>- ចេះវិភាគទិន្នន័យនិងប្រើប្រាស់ឧបករណ៍សម្រាប់ការងារស្ទង់មតិ<br>- ប៉ិនប្រសប់ក្នុងការប្រើប្រាស់ទ្រឹស្តីនិងបច្ចេកទេសប្រឹក្សាអាជីពក្នុងកាលៈទេសៈផ្សេងៗ ដូចជាក្នុងពេលផ្តល់ប្រឹក្សាទល់មុខម្នាក់ទល់ម្នាក់ ជាក្រុមតូចៗ និងក្នុងពេលបង្រៀនម៉ោងមគ្គុទ្ទេសក៍ក្នុងថ្នាក់ជាដើម<br>- មានជំនាញកសាងភាពជាដៃគូរវាងសាលារៀននិងសហគមន៍មូលដ្ឋាន និងការកសាងបណ្តាញ<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ ជៀសវាងការសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាព និងវិស័យអប់រំ។ |

## ១១- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សាប្រឹក្សាគរុកោសល្យ (លេខកូដ : PED011)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សាប្រឹក្សាគរុកោសល្យ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

- ផ្តល់ការប្រឹក្សានិងយោបល់ជូនគ្រូបង្រៀនផ្សេងទាក់ទងវិធីសាស្ត្របង្រៀន និងគ្រប់គ្រងថ្នាក់រៀន ដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន
- ចូលរួមវាយតម្លៃលទ្ធផលនិងសមត្ថភាពបង្រៀនរបស់គ្រូបង្រៀនដើម្បីផ្តល់យោបល់ និងកែលម្អការបង្រៀន
- ផ្តល់ការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀននិងបទពិសោធដល់គ្រូបង្រៀន
- ចែករំលែកនិងតម្រង់ទិសវិជ្ជាជីវៈនិងបង្កើនកម្រិតចំណេះជំនាញក្នុងការបង្រៀន ការគ្រប់គ្រងថ្នាក់រៀនដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពសិក្សារបស់សិស្ស
- ស្រាវជ្រាវវិធីសាស្ត្របង្រៀនថ្មី និងធ្វើបទបង្ហាញជាប្រចាំដើម្បីជំរុញការងាររៀននិងបង្រៀន
- រិះរកវិធីក្នុងការទប់ទល់ ឬដោះស្រាយទៅនឹងអាកប្បកិរិយាមិនសមរម្យក្នុងចំណោមគ្រូបង្រៀន
- ផ្តល់ដំបូន្មានឬមតិយោបល់ត្រឡប់ដើម្បីដោះស្រាយជុំវិញកិច្ចការរៀននិងបង្រៀន
- អនុវត្តតាមតួនាទីភារកិច្ចដូចមានចែងក្នុងនិយាមប្រើប្រាស់បុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)

៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ ប្រឹក្សាគរុកោសល្យ អភិវឌ្ឍកម្មវិធីសិក្សាឬជំនាញឯកទេសពាក់ព័ន្ធ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |

<table>
<tr>
<td rowspan="2">៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព)</td>
<td>ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងលើវិធីសាស្ត្របង្រៀននិងការគ្រប់គ្រងថ្នាក់រៀន ដើម្បីផ្តល់ការណែនាំ និងប្រឹក្សាគ្រូផ្សេងទាក់ទងនឹងការបង្រៀន<br>- មានជំនាញប្រឹក្សាយោបល់និងទំនាក់ទំនងល្អដើម្បីធ្វើការជាមួយគ្រូផ្សេង និងគណៈគ្រប់គ្រងសាលារៀន<br>- មានសមត្ថភាពរៀបចំផែនការប្រចាំឆ្នាំ ផែនការ៣ឆ្នាំ និងផែនការ៥ឆ្នាំ យោងតាមតម្រូវការសាលារៀន<br>- មានសមត្ថភាពត្រួតពិនិត្យកិច្ចការរៀននិងបង្រៀនរបស់គ្រូ<br>- មានជំនាញស្ទង់មតិ និងយកយោបល់ត្រឡប់មកវិភាគដើម្បីស្វែងរកដំណោះស្រាយសមរម្យសម្រាប់ជំរុញដល់កិច្ចការរៀននិងបង្រៀន<br>- មានជំនាញទំនាក់ទំនងសហគមន៍ដើម្បីការអភិវឌ្ឍសាលារៀន<br>- មានជំនាញដឹកនាំសិស្សានុសិស្សសិក្សាបែបគម្រោង<br>- អាចទទួលខុសត្រូវការងារនិងភារកិច្ចផ្សេងទៀតយោងតាមការចាត់តាំងរបស់សាលារៀន<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។</td>
</tr>
<tr>
<td>ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ ជៀសវាងការសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។</td>
</tr>
</table>

## ១២- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សាកសិកម្ម (លេខកូដ : PED012)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សាកសិកម្ម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖(ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- ដឹកនាំនិងរៀបចំបរិស្ថានបៃតងរបស់សាលារៀន<br>- បង្រៀនបច្ចេកទេសកសិកម្មនិងវិធីដាំដុះស្រូវ បន្លែ ផ្លែឈើ និងដំណាំផ្សេងៗ<br>- ផ្តល់ចំណេះដឹងអំពីបច្ចេកទេសប្រើប្រាស់ជីធម្មជាតិ និងជីសរីរាង្គ<br>- ផ្សព្វផ្សាយសុវត្ថិភាពចំណីអាហារនិងបន្លែផ្លែឈើធម្មជាតិ<br>- ដឹកនាំសិស្សធ្វើគម្រោងនិងបង្កើតស្នាដៃផ្សេងៗ<br>- ដឹកនាំសិស្សអនុវត្តផ្ទាល់លើការដាំដុះ និងលើកកម្ពស់សាលាមួយផលិតផលមួយ<br>- ដឹកនាំសិស្សពិសោធ ជ្រើសរើសពូជ និងបង្កាត់ពូជរុក្ខជាតិ<br>- ផ្សព្វផ្សាយពីសារសំខាន់នៃបរិស្ថានបៃតង និងបណ្តុះស្មារតីស្រលាញ់បរិស្ថាន<br>- ផ្សារភ្ជាប់ការងារកសិកម្មសាលារៀនជាមួយសហគមន៍<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឡើង |
| | ជំនាញឯកទេស៖ កសិកម្ម វិជ្ជាជីវៈកសិកម្ម ឬជំនាញឯកទេសពាក់ព័ន្ធ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមតម្រូវការរបស់អង្គភាព |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀនអប់រំបច្ចេកទេស និងការវាយតម្លៃសមត្ថភាពសិស្ស<br>- ចេះរៀបចំផែនការបង្រៀននិងរដ្ឋបាលគ្រូ(កិច្ចតែងការបង្រៀន សន្លឹកការងារប្រតិបត្តិ រដ្ឋបាលថ្នាក់រៀន និងឯកសារពាក់ព័ន្ធ)<br>- ចេះរៀបចំកិច្ចការរដ្ឋបាលសាលារៀន និងទទួលបន្ទុកមន្ទីរពិសោធន៍យោងតាមតម្រូវការសាលារៀន<br>- ចេះដឹកនាំសិស្សានុសិស្សសិក្សាបែបគម្រោង/ស្រាវជ្រាវ<br>- ចេះបង្រៀនសិស្សឱ្យអនុវត្តផ្ទាល់នៅបន្ទប់ប្រតិបត្តិ ឬកសិដ្ឋាន<br>- មានទំនាក់ទំនងសហគមន៍ រោងចក្រ សហគ្រាស ឬកសិដ្ឋានសម្រាប់ការធ្វើទស្សនកិច្ចសិក្សា និងប្រតិបត្តិទ្រឹស្តី<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពច្បាប់ការងារ វិន័យអង្គភាព និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានឆន្ទៈ មនសិការវិជ្ជាជីវៈ និងភក្តីភាពចំពោះការចូលរួមអភិវឌ្ឍន៍វិស័យអប់រំ<br>- គោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន<br>- មានសាមគ្គីភាព ចែករំលែក និងគាំទ្រដល់ការអភិវឌ្ឍអង្គភាព<br>- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ត្រូវរក្សាសុខភាពល្អ ជៀសវាងការសេពគ្រឿងស្រវឹង និងជក់បារីក្នុងពេលបំពេញការងារ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មិនប្រើប្រាស់ពាក្យសម្តី ហិង្សា ឬអំពើអសីលធម៌គ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងវិស័យអប់រំ។ |

## ១៣- ការពិពណ៌នាមុខតំណែងគ្រូបង្រៀនបឋមសិក្សាពហុភាសាជនជាតិដើមភាគតិច (លេខកូដ : PED013)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូបង្រៀនបឋមសិក្សាពហុភាសាជនជាតិដើមភាគតិច |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

- បង្រៀនមេរៀនតាមកម្មវិធីពហុភាសាដោយប្រើភាសាមាតុភូមិនិងភាសាខ្មែរ ស្របតាមសមត្ថភាពជនជាតិដើមភាគតិច
- កែសម្រួលមេរៀននិងសម្ភារៈបង្រៀនឱ្យសមស្របនឹងវប្បធម៌ជនជាតិដើមភាគតិច
- សិក្សាស្រាវជ្រាវនិងចងក្រងវប្បធម៌អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច
- ជំរុញការផ្សព្វផ្សាយវប្បធម៌អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច
- សិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រទាក់ទងនឹងវប្បធម៌អរិយធម៌របស់ជនជាតិដើមភាគតិច
- ស្រាវជ្រាវប្រវត្តិសាស្ត្រដោយប្រើប្រាស់អក្សរខ្មែរដើម្បីកត់សំនៀងដើមរបស់ជនជាតិដើមភាគតិច
- បង្កើតខ្សែអ៊័តសំនៀងនិងរក្សាទុកទិន្នន័យ
